# សន្ទរកថាបើកសន្និសីទជាតិ ស្ដីពី

# កម្ពុជា ១០ឆ្នាំនៃការចូលជាសមាជិកអាស៊ាន

## ថ្លែងដោយ សម្ដេច នរោត្ដម សិរីវុឌ្ឍ ព្រះប្រធានស្ថាបនិក

## និងជាព្រះប្រធានក្រុមប្រឹក្សាភិបាលវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

## និងជាព្រះរាជឧត្ដមទីប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

**ឯកឧត្ដម លោកជំទាវ អស់លោក លោកស្រី**

**ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ជាទីគោរព !**

ជាបឋមក្នុងនាមក្រុមប្រឹក្សាភិបាល និងក្រុមលេខាធិការប្រតិបត្តិរបស់វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការនិងសន្តិភាព និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ សូមសម្ដែងនូវភារកិច្ចស្វាគមន៍យ៉ាងរាក់ទាក់ចំពោះវត្តមានឯកឧត្ដម លោកជំទាវ តំណាងអង្គទូត តំណាងអង្គការជាតិនិងអន្តរជាតិ អស់លោក លោកស្រីដែលបានអញ្ជើញចូលរួមនៅក្នុងសន្និសីទជាតិ ស្ដីពី **កម្ពុជា ១០ឆ្នាំនៃការចូលជាសមាជិកអាស៊ាន** ដែលប្រារព្ធធ្វើឡើងនៅរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជានាឱកាសនេះ។

សូមថ្លែងអំណរគុណចំពោះមូលនិធិហ្វ្រីឌ្រិច-អេប៊ែត ដែលមានលោកស្រីបណ្ឌិត ស្ដេហ្វានី អេលី (Dr. Stefanie Elies) ជាប្រធានតំបន់ សំរាប់សហប្រតិបត្តិការភូមិភាគអាស៊ីប្រចាំប្រទេសសិង្ហបុរី ដែលបានផ្ដួចផ្ដើមគំនិត ឧបត្ថម្ភ និងសហការយ៉ាងជិតស្និទ្ធជាមួយវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព រៀបចំសន្និសីទជាតិដ៏មានសារៈសំខាន់នេះនៅប្រទេសយើងខ្ញុំ។

វត្តមានរបស់ឯកឧត្ដម លោកជំទាវ អស់លោក លោកស្រីជាភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិនាពេលនេះ គឺជាការឆ្លុះបញ្ចាំងអោយឃើញនូវស្មារតីឧបត្ថម្ភគាំទ្រ និងចូលរួមចំណែកដល់កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងពង្រឹងសមត្ថភាព តួនាទីកម្ពុជាក្នុងតំបន់ ក៏ដូចលើឆាកអន្តរជាតិ។

ការរៀបចំសន្និសីទជាតិ ស្ដីពី **កម្ពុជា ១០ឆ្នាំនៃការចូលជាសមាជិកអាស៊ាន** នាពេលនេះ ជាវេទិកាលើកទី២របស់វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិនិងសន្តិភាព បន្ទាប់ពីវេទិកាលើកទី១បានប្រារព្ធធ្វើកាលពីឆ្នាំ២០០៥ ដើម្បីពិនិត្យមើលផងដែរទៅលើសមាជិកភាព **កម្ពុជា ៥ឆ្នាំ ក្រោយអាស៊ាន**។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិជាទីមេត្រី!**

បន្ទាប់ពីបានចូលជាសមាជិកពេញសិទ្ធិរបស់អាស៊ាននៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៩ កម្ពុជាបាន ខិតខំបង្កើនកិច្ចសហប្រតិបត្តិការជាមួយសមាជិកដទៃទៀតរបស់អាស៊ាន ក៏ដូចជាពង្រីកទំនាក់ទំនងការទូត ពាណិជ្ជកម្ម និងវិស័យផ្សេងៗទៀតជាច្រើន ជាមួយដៃគូរក្នុងអាស៊ាន អាស៊ានបូក៣ អាស៊ានបូក៣បូក៣ រឺអាស៊ានបូក៦ អាស៊ាន-អឺរ៉ុប ហើយថ្មីៗនេះកិច្ចសហប្រតិបត្តិរវាងអាមេរិក-អាស៊ាន ក៏កំពុងតែបោះជំហាន ទៅមុខយ៉ាងប្រសើរ ។

ក្នុងឋានៈជាសមាជិកពេញសិទ្ធិរបស់អាស៊ាន កម្ពុជាបានចូលរួមយ៉ាងសកម្មគ្រប់សកម្មភាពរបស់ អាស៊ាន ដូចជាកិច្ចប្រជុំកំពូលអាស៊ាន កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន កិច្ចប្រជុំនៃវេទិកាផ្សេងៗរបស់ អាស៊ាន . . .។ល។ លើសពីនេះទៀតកម្ពុជាបានចូលរួមធ្វើគោលនយោបាយ និងច្បាប់ផ្សេងៗរបស់អាស៊ាន ដូចជាធម្មនុញ្ញអាស៊ាន អង្គការសិទ្ធមនុស្សអាស៊ាន ជាពិសេសកម្ពុជាបានក្លាយជាម្ចាស់ផ្ទះប្តូរវេននៃកិច្ចប្រជុំ កំពូលអាស៊ាន និងដៃគូរសន្ទនាផ្សេងៗរបស់អាស៊ាន ហើយឆ្នាំកន្លងទៅនេះកម្ពុជាបានទទួលធ្វើជាម្ចាស់ផ្ទះ រៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-អឺរ៉ុប ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី ទោះបីជាកម្ពុជាទទួលបាននូវផលប្រយោជន៍ច្រើនពីអាស៊ាន ក្តី ក៏កម្ពុជានៅមានការប្រឈមច្រើនទៀតដែលត្រូវអោយយើងទាំងអស់គ្នាចូលរួមដោះស្រាយ ។ ក្នុងនោះ ការប្រឈមដ៏សំខាន់របស់កម្ពុជាក្នុងសមាហរណកម្មអាស៊ាន គឺការកាត់បន្ថយភាពគម្លាតគ្នារវាងសមាជិក អាស៊ានថ្មី៤ (កម្ពុជា វៀតណាម ឡាវ ភូមា) ជាមួយសមាជិកអាស៊ានចាស់៦ទៀត ។

អង្គសន្និសីទជាតិដែលធ្វើឡើងនៅថ្ងៃនេះ គឺជាវេទិកាចំហមួយសម្រាប់ធ្វើការសិក្សាបន្ថែម និងវិភាគ កែសម្រួលទៅលើបញ្ហាគន្លឹះនានា ដែលជាការប្រឈម និងកាលានុវត្តភាពរបស់កម្ពុជាក្នុងសមាគមន៍អាស៊ាន ។

**វត្ថុបំណងនៃវេទិកា និងអង្គសន្និសីទជាតិនេះ គឺដើម្បី :**

- ផ្សព្វផ្សាយព័ត៌មានស្តីពីគោលដៅអនាគតរបស់អាស៊ាន និងបញ្ហាប្រឈមផ្សេងៗដែល អាស៊ានបានជួប ដើម្បីអោយប្រជាពលរដ្ឋកម្ពុជាមានការយល់ដឹងកាន់តែប្រសើរអំពីការអភិវឌ្ឍន៍ទាំងឡាយ របស់អាស៊ាន ។

- ជំរុញនិងលើកកំពស់ការពិភាក្សាក្នុងន័យស្ថាបនា រវាងសាធារណៈជន និងអ្នកធ្វើសេចក្តី សំរេចចិត្តទាំងឡាយ ដើម្បីលើកឡើងនូវបញ្ហាកង្វល់ នឹងបានជាអនុសាសន៍ដាក់ជូនទៅរាជរដ្ឋាភិបាល ។

- ផ្តោតការយកចិត្តទុកដាក់លើបញ្ហាទាំងឡាយ ដែលអាចជះឥទ្ធិពលមកលើប្រជាជនកម្ពុជា និងប្រទេសកម្ពុជាទាំងមូល ។

- ផ្តល់ទស្សនៈទានអំពីការប្រឈមនានាក្នុងអាស៊ាន ដូចជាធម្មនុញ្ញអាស៊ាន អង្គការសិទ្ធិមនុស្សអស៊ាន AFTA និងបញ្ហាផ្សេងៗទៀត។

- លើកកំពស់សមត្ថភាព និងការយល់ដឹងរបស់ប្រជាពលរដ្ឋ និងសង្គមស៊ីវិលកម្ពុជា ដើម្បីឆ្លើយតបនឹងតំរូវការផ្សេងៗរបស់អាស៊ាន។

ម្យ៉ាងវិញទៀតអង្គសន្និសីទជាតិនេះ នឹងផ្តល់នូវឱកាសដល់ភាគីទាំងអស់មកពីគ្រប់មជ្ឈដ្ឋានក្នុងការបញ្ចេញនូវគំនិត ទស្សនៈ យោបល់ចូលរួមក្នុងការស្ថាបនាកម្ពុជា និងតំបន់អាស៊ាន។ ជាមួយនេះដែរ ខ្ញុំសង្ឃឹមថាក្នុងរយៈពេលពេញមួយថ្ងៃនេះ យើងទាំងអស់គ្នាប្រាកដជាមានការមមាញឹកនៅក្នុងការផ្លាស់ប្តូរបទពិសោធន៍ និងទស្សនៈ វិស័យផ្សេងៗទៅវិញទៅមក ដើម្បីស្វែងយល់អោយបានល្អិតល្អន់បន្ថែម ទៀតពីការប្រឈម កាលានុវត្តភាព និងទិសដៅអនាគតរបស់កម្ពុជាក្នុងសមាគមអាស៊ាន។

តាមរយៈអង្គសន្និសីទជាតិនេះ ខ្ញុំសូមស្នើរដល់អ្នកចូលរួមទាំងអស់ សូមកុំមានការខ្លាចរអាក្នុងការពិគ្រោះយោបល់និងផ្លាស់ប្តូរទស្សនៈដល់វាគ្មិនដែលអញ្ជើញមកពីមជ្ឈដ្ឋានផ្សេងៗ ទាំងរាជរដ្ឋាភិបាល និងសង្គមស៊ីវិល។ ទន្ទឹមនឹងនេះ យើងខ្ញុំក៏សូមស្នើរដល់វាគ្មិននានាសូមមេត្តាផ្តល់នូវគំនិតនិងបទពិសោធន៍ដែលឯកឧត្តម អស់លោកធ្លាប់បានឆ្លងកាត់សម្រាប់ជាមេរៀនដល់យើងខ្ញុំ។ យើងខ្ញុំក៏សង្ឃឹម និងជឿជាក់ថាសន្និសីទជាតិនេះនឹងក្លាយទៅជាវេទិកាផ្លាស់ប្តូរមតិគ្នាក្នុងន័យកសាងទំនុកចិត្ត និងទំនាក់ទំនងល្អដើម្បីសំរេចបាននូវអាស៊ានមួយដែលមានសំលេងមួយ និងអត្តសញ្ញាណមួយ។

ជាថ្មីម្តងទៀតតាងនាមអោយអង្គសន្និសីទជាតិទាំងមូល ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិ សមាជិក សមាជិកា ទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃអញ្ជើញមកចូលរួមក្នុងសន្និសីទជាតិនេះ។ ម្យ៉ាងវិញទៀតយើងខ្ញុំសូមថ្លែងអំណរគុណចំពោះមូលនិធិ ហ្វ្រីឌ្រិច អេប៊ែត(FES) ដែលមានលោកស្រីបណ្ឌិត ស្តេហ្វានី អេលី (Dr.Stefanie Elies) ជាតំណាងដែលបានជួយឧបត្ថម្ភថវិកាដល់អង្គសន្និសីទជាតិនេះ។

មុននឹងបញ្ចប់ យើងខ្ញុំមានកិត្តិយស សូមគោរពជូនពរភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាសមាជិក សមាជិកា អង្គសន្និសីទជាតិទាំងមូលសូមប្រកបដោយពុទ្ធពរទាំង៤ប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ។

**សូមអរគុណ**